**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៤៨ សហវ

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០២*

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង់ថ្លៃប្រើប្រាស់ផ្លូវសំរាប់យានយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរលើផងផ្លូវជាតិលេខ៤

※※※※※

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកត/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់អំពីប្រព័ន្ធហិរញ្ញវត្ថុ.
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ .
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ .
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០១ ។

- បានឃើញព្រះរាជក្រមលេខ នស កម ០១៩៦-០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន.
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ-បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន.
- បានឃើញកិច្ចព្រមព្រៀងសម្បទាន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០១ រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន អេហ្សិត ឱស្រ្តីប្ស៊ីប៊ូហ្សិន ស្តីពីការថែទាំជួសជុលផ្លូវជាតិលេខ៤.
- បានឃើញចំណារបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០២ លើលិខិតលេខ ១៨៩៤ សក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០០២ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន .
- បានឃើញលិខិតលេខ ១៩៦៨ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី.
- បានឃើញលិខិតលេខ ១៩៦៩ សជណ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី.
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០១ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូរពិភាក្សាការងារជាមួយវិស័យឯកជន.
- តាមការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន.

## សំរេច

**ប្រការ១:** កំណត់បណ្តាយានយន្តគ្រប់ប្រភេទ ដូចមានចែងក្នុងប្រការ២ ដែលធ្វើចរាចរលើដងផ្លូវជាតិលេខ៤ ចាំបាច់ត្រូវបង់ប្រាក់ ជាប្រាក់រៀល ឬប្រាក់ដុល្លារ សំរាប់សេវាកម្មថែទាំ និងជួសជុលផ្លូវនេះ ។

**ប្រការ២:** កំណត់តំលៃយានយន្តគ្រប់ប្រភេទត្រូវបង់ ( មួយបញ្ជរបង់ប្រាក់ ) ដូចខាងក្រោម :

1- រថយន្តធុនធ្ងន់ដោយមានសណ្តោងរ៉ឺម៉កមិនគិតលើសពី 40ហ្វីត 6,30 ដុល្លារអាមេរិក
2- រថយន្តធុនធ្ងន់ដែលមានតួវែង មិនគិតលើសពី 20ហ្វីត 4,90 ដុល្លារអាមេរិក
3- រថយន្តធុនធ្ងន់ :
  + រថយន្តស៊ីទែនប្រេង 6,00 ដុល្លារអាមេរិក
  + រថយន្តលាតដឹកផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម 4,20 ដុល្លារអាមេរិក
  + រថយន្តបែន (ដឹកដី, ថ្ម, គ្រួស, ខ្សាច់) 2,50 ដុល្លារអាមេរិក
4- រថយន្តដឹកទំនិញធុនស្រាល :
  + រថយន្តដឹកទំនិញចាប់ពី : 3 តោន → 6 តោន 2,50 ដុល្លារអាមេរិក
  + រថយន្តដឹកទំនិញចាប់ពី : 2 តោន → ក្រោម 3 តោន 2,00 ដុល្លារអាមេរិក
  + រថយន្តដឹកទំនិញចាប់ពី : 1 តោន → ក្រោម 2 តោន 1,50 ដុល្លារអាមេរិក
5- រថយន្ត Bus 2,50 ដុល្លារអាមេរិក
6- រថយន្ត Mini Bus (12 កៅអី) [illegible],50 ដុល្លារអាមេរិក
7- រថយន្តតាក់ស៊ី 1,00 ដុល្លារអាមេរិក(ពុំទាន់យកថ្លៃផ្លូវ)
8- រថយន្តទេសចរគ្រួសារ 1,00 ដុល្លារអាមេរិក(ពុំទាន់យកថ្លៃផ្លូវ)

**ប្រការ៣:** រាល់យានយន្តគ្រប់ប្រភេទដែលធ្វើចរាចរលើផ្លូវជាតិលេខ៤ ត្រូវទទួលការផាកពិន័យអំពីការផ្ទុកលើសទម្ងន់ដោយអនុវត្តតាមច្បាប់ និងអនុក្រឹត្យដោយគ្មានការលើកលែង ។

**ប្រការ៤:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសាធារណការ និងដឹកជញ្ជូន គ្រប់ក្រសួង ស្ថាប័នខេត្ត-ក្រុង ដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីពេលដាក់អោយដំណើរការអាជីវកម្មជាផ្លូវការ តទៅ ។

**ប្រការ៥:** ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អ្នកសម្របសម្រួលក្រុមការងារនៃ
វេទិការាជរដ្ឋាភិបាល-វិស័យឯកជន

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងសាធារណការ និងដឹកជញ្ជូន
រដ្ឋលេខាធិការ

ហ៊ោ អ៊ុងពេក

*កន្លែងទទួល:*

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រុមហ៊ុន អេហ្សិត
- ក្រុមហ៊ុនដឹកជញ្ជូន

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ